ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

**ជូនចំពោះ**
**ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

ខ្ញុំបានទទួលរួចហើយនូវលិខិតលេខ ៤០៤១ អពដ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ របស់ **ឯកឧត្តម** ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃអគ្គនាយកដ្ឋានពន្ធដារ ដែលបានផ្ញើជូនពរ និងអបអរសាទរចំពោះរូបខ្ញុំ ក្នុងឱកាសដែលខ្ញុំត្រូវបាន **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជទាននូវគោរមងារជា **សម្តេចក្រឡាហោម ស ខេង** ។

ខ្ញុំចាត់ទុកថា ការទទួលគោរមងារដ៏ថ្លៃថ្លាពី **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** គឺបានមកដោយមានការចូលរួមជួយឧបត្ថម្ភគាំទ្រលើកទឹកចិត្តពីសំណាក់ថ្នាក់ដឹកនាំប្រមុខរាជរដ្ឋាភិបាល ពីឯកឧត្តម និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងប្រជាពលរដ្ឋនៅទូទាំងប្រទេស។

ជាមួយនឹងការទទួលបាននូវគោរមងារដ៏ថ្លៃថ្លានេះ ដើម្បីជាផលប្រយោជន៍ជាតិ និងមាតុភូមិដ៏ឧត្តុង្គឧត្តម ខ្ញុំសូមសម្តែងនូវឆន្ទៈដ៏មោះមុត និងស្មោះសជានិច្ច ក្នុងការខិតខំបំពេញភារកិច្ចឱ្យកាន់តែល្អប្រសើរជាបន្តទៀត ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងបុព្វហេតុបម្រើ ជាតិ សាសនា ព្រះមហាក្សត្រ។

ក្នុងឱកាសដ៏វិសេសថ្លៃថ្លានេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងសូមជូនពរចំពោះ **ឯកឧត្តម** និងថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃអគ្គនាយកដ្ឋានពន្ធដារ សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ វិបុលសុខ សុភមង្គល និងសម្រេចបានជោគជ័យគ្រប់ភារកិច្ច ។

សូម **ឯកឧត្តម** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០១៥
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**